# ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៧

ស្តីពី

## ការបង្កើតគណៈឱសថការីកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

- បានទ្រង់យល់ព្រះរាជក្រមលេខជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០១០

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើត**គណៈឱសថការីកម្ពុជា**មួយ ដើម្បីប្រមូលផ្តុំឱសថការីទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់ អាចប្រកបវិជ្ជាជីវៈឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថា ឱសថការី ក្នុងព្រះរាជក្រឹត្យនេះ គឺនីតិជនដែលមានសញ្ញាបត្រឱសថសាស្ត្រ ចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រឱសថសាស្ត្រ ចេញដោយគ្រឹះស្ថានឧត្តមសិក្សាដែលបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ឱសថការីទាំងអស់ដែលប្រកបវិជ្ជាជីវៈឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ។

## ជំពូកទី២
## បេសកកម្មនិងតួនាទីរបស់គណៈឱសថការីកម្ពុជា
## ផ្នែកទី១
## បេសកកម្ម

**មាត្រា២.-**

គណៈឱសថការីកម្ពុជា តាមរយៈការចូលរួមការបំពេញសេវាសាធារណៈផ្នែកសុខភាពសាធារណៈ ទទួលបាននូវបុព្វសិទ្ធិដែលរដ្ឋប្រគល់ជូន ។

គណៈឱសថការីកម្ពុជា ធានាមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍ សីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្តីភាពចាំបាច់ ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈឱសថការីកម្ពុជា ធានាមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ ព្រមទាំងបទប្បញ្ញត្តិនានាដែលមានចែងនៅក្នុងក្រមសីលធម៌ឱសថការី ។

គណៈឱសថការីកម្ពុជា ធានាការពារកិត្តិយស និងឥស្សរភាពរបស់វិជ្ជាជីវៈឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រ ។

គណៈឱសថការីកម្ពុជា បំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈឱសថការីរាជធានី ខេត្តដែលសរសេរអក្សរកាត់ថាគ.ឱ.រ.ខ. ក្រុមប្រឹក្សាគណៈឱសថការីភូមិភាគដែលសរសេរអក្សរកាត់ថា គ.ឱ.ភ. និងក្រុមប្រឹក្សាគណៈឱសថការីជាតិដែលសរសេរអក្សរកាត់ថាគ.ឱ.ជ. ។

## ផ្នែកទី២
## តួនាទីសីលធម៌

**មាត្រា៣.**_

គណៈឱសថការីកម្ពុជា មានបន្ទុករៀបរៀងក្រមសីលធម៌ឱសថការី យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈក្នុងការវិវឌ្ឍ ខាងបច្ចេកទេស សេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ។

គណៈឱសថការីកម្ពុជា ត្រូវឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ និងសេចក្តីគោរពប្រណិប័តន៍របស់ឱសថការី ។

គណៈឱសថការីកម្ពុជា ជាអង្គការស្វយ័ត ។ ការចំណាយ ការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាព ការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី៣
## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា៤.**_

ការចាត់ចែងអំណាចត្រូវអនុលោមតាមបទបញ្ជាគណៈឱសថការីកម្ពុជា ។

គណៈឱសថការីកម្ពុជា ត្រូវរៀបចំធ្វើនិងថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមឱសថការី ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះក្នុងបញ្ជីរាយនាមឱសថការី គឺដើម្បីបំពេញការងារឱសថសាស្ត្រ និងអមវេជ្ជសាស្ត្រ ។

គណៈឱសថការីកម្ពុជា ជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រនេះ ។

## ផ្នែកទី៤
## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា៥.**_

ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការងារវិន័យវិជ្ជាជីវៈ គ.ឱ.ជ. ត្រូវអនុវត្តការងារជាយន្តការយុត្តាធិការ ។

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ឱសថការីណាម្នាក់ ទៅគណៈឱសថការីកម្ពុជា មិនមែនជាឧបសគ្គក្នុងការប្តឹងបណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនេះទៅតុលាការឡើយ ។

## ផ្នែកទី៥

## តួនាទីពិភាក្សាផ្តល់យោបល់

**មាត្រា៦.-**

គណៈឱសថការីកម្ពុជាអាចត្រូវបានអញ្ជើញឱ្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឱសថសាស្ត្រទាំងឡាយ ។

## ផ្នែកទី៦

## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា៧.-**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យល្អដល់ឱសថការី និងគ្រួសាររបស់គេ។ ការជួយសង្គ្រោះគ្នា ត្រូវរៀបចំតាមបែបបទដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុង អនុម័តដោយមហាសន្និបាតៈ

- គណៈឱសថការីកម្ពុជា ត្រូវមានក្នុងថវិការបស់ខ្លួននូវប្រាក់បម្រុងសម្រាប់សង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាម១ ក្នុងករណីសមរម្យដល់គ្រួសារឱសថការី ដែលត្រូវរងទុក្ខលំបាក
- គណៈឱសថការីកម្ពុជា ត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមឱសថការីកម្ពុជាម្នាក់ជាសមាជិក
- គណៈកម្មការនេះចាត់ចែងឱ្យមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់ភាគទានរបស់ឱសថការីម្នាក់១ ដែលចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ។

# ជំពូកទី៣

# រចនាសម្ព័ន្ធ

## ផ្នែកទី១

## ក្រុមប្រឹក្សាគណៈឱសថការីរាជធានី ខេត្ត

**មាត្រា៨.-**

**ក.ឱ.រ.ខ.** ត្រូវបានបង្កើតនៅតាមរាជធានី ខេត្តនីមួយ១ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

រាជធានី ខេត្ត ដែលមានចំនួនឱសថការីតិចជាង១០(ដប់)រូប ត្រូវបញ្ជូនទៅខេត្តដែលនៅជិតជាងគេ ដើម្បីបង្កើតក្រុមប្រឹក្សាគណៈឱសថការីរួមគ្នា។

**មាត្រា៩.-**

**ក.ឱ.រ.ខ.** ត្រូវមានសមាជិកពេញសិទ្ធិចំនួន៣(បី)រូប និងសមាជិកជំនួសចំនួន៣(បី)រូប ក្នុងករណីដែលឱសថការីចុះឈ្មោះមានចំនួនមិនលើសពី៣០(សាមសិប)រូប។ ចំនួននេះនឹងឡើងទៅដល់៥(ប្រាំ) ៧(ប្រាំពីរ) ៩(ប្រាំបួន) ១១(ដប់មួយ)

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឬ១៣(ដប់បី)រូប ប្រសិនបើឱសថការីចុះបញ្ជីមានចំនួនពី ៣០(សាមសិប)រូប ៥០(ហាសិប)រូប ១០០(មួយរយ)រូប ១ ០០០ (មួយពាន់)រូប ឬ២ ០០០ (ពីរពាន់)រូប ។

**មាត្រា១០.-**

គ.ឱ.រ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយឱសថការីទាំងឡាយ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីរបស់គ.ឱ.រ.ខ.សម្រាប់រយៈពេល៦ (ប្រាំមួយ) ឆ្នាំ ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងសមាសភាពនៃការិយាល័យរបស់ខ្លួននៅក្នុងរយៈពេល២(ពីរ)ឆ្នាំម្តង ក្រោយពេលធ្វើការផ្លាស់ប្តូរចំនួន១/៣(មួយភាគបី)នៃសមាជិកក្រុមប្រឹក្សា ហើយត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង អំពីករណីដែលសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

សមាសភាពការិយាល័យរបស់គ.ឱ.រ.ខ. រួមមានប្រធានក្រុមប្រឹក្សា១(មួយ)រូប អនុប្រធាន១(មួយ)រូប លេខាធិការ១ (មួយ)រូប ហេរញ្ញិក១ (មួយ)រូប និងសមាជិក១ (មួយ)រូប ។

**មាត្រា១១.-**

គ.ឱ.រ.ខ.បំពេញការងារនៅក្នុងក្របខណ្ឌរាជធានីខេត្តរបស់ខ្លួន និងក្រោមការត្រួតពិនិត្យរបស់គណៈឱសថការីកម្ពុជា ចំពោះសមត្ថកិច្ចទូទៅទាំងឡាយដែលមានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ។

គ.ឱ.រ.ខ.សម្រេចអារកាត់ក្នុងការចុះឈ្មោះឱសថការី ដែលបានបំពេញលក្ខខណ្ឌតាមមាត្រា៤ថ្មី នៃជំពូកទី១ មាត្រា៧ និង មាត្រា៨ថ្មីនៃជំពូកទី៣ នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ មាត្រា៦នៃជំពូកទី២ និងមាត្រា១០នៃជំពូកទី៣នៃច្បាប់ស្តីពីការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ក្នុងបញ្ជីរបស់គ.ឱ.រ.ខ. ។

គ.ឱ.រ.ខ.មិនប្រកាន់ភេទ ជំនឿ សាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា១២.-**

គ.ឱ.រ.ខ.ពុំមានអំណាចដាក់វិន័យទេ ។ បើមានពាក្យប្តឹងចំពោះឱសថការីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន គ.ឱ.រ.ខ. ត្រូវបញ្ជូនបណ្តឹងនេះទៅគ.ឱ.ក.ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា១៣.-**

ប្រធានជាតំណាងរបស់គ.ឱ.រ.ខ.នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះរាជវាំង

មាត្រា១៤._

ការប្រជុំនៃគ.ឱ.រ.ខ.មិនធ្វើជាសាធារណៈឡើយ ។ រាល់ការប្រជុំបើមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាពសម្រេច ។ ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាគ្រាន់តែមានសំឡេងពិគ្រោះយោបល់ ។ គ.ឱ.រ.ខ.អាចអញ្ជើញទីប្រឹក្សាច្បាប់១(មួយ)រូប មកចូលរួមក្នុងអង្គប្រជុំ ។

មាត្រា១៥._

ឱសថការីនៅតាមបណ្តារាជធានី ខេត្ត ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជីដែលកាន់កាប់ជាប្រចាំដោយ គ.ឱ.រ.ខ.ពាក់ព័ន្ធ ។ ឱសថការីដែលសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ត្រូវតែមានសញ្ញាបត្រឱសថការីចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រ និងបានបំពេញលក្ខខណ្ឌច្បាប់ និងក្រមសីលធម៌ ដែលបានកំណត់ ។

ឱសថការីអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីគណៈឱសថការីនៃរាជធានី ខេត្ត ដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

មាត្រា១៦._

គ.ឱ.រ.ខ.ត្រូវសម្រេចលើសំណើសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលពាក្យសុំដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេល១(មួយ)សប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅឱសថការីសាមី ។ បើមានការបដិសេធលើសំណើសុំចុះឈ្មោះ គ.ឱ.រ.ខ.ត្រូវបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ។

បន្ទាប់ពីការអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីរាជធានីខេត្តនីមួយៗរួចហើយ គ.ឱ.រ.ខ.ត្រូវជូនដំណឹងយ៉ាងយូរ២(ពីរ)សប្តាហ៍ ទៅអាជ្ញាធររាជធានីខេត្ត ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីខេត្តពាក់ព័ន្ធ និងទៅគ.ឱ.ជ. ។

មាត្រា១៧._

ក្រោយពេលអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីរាជធានី ខេត្ត ដែលខ្លួនកំពុងប្រកបវិជ្ជាជីវៈ ឱសថការីអាចប្រកបវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រ នៅរាជធានី ខេត្ត ដែលខ្លួនចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅឋានទៅប្រកបវិជ្ជាជីវៈនៅក្រៅរាជធានី ខេត្ត ដែលខ្លួនចុះឈ្មោះ ឱសថការីត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសាជាថ្មីទៅគ.ឱ.រ.ខ. ដែលខ្លួនទៅរស់នៅប្រកបវិជ្ជាជីវៈ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

មាត្រា១៨._

គ.ខ្ញ.រ.ខ. ត្រូវទទួលបណ្តឹងជំទាស់ពីគ.ខ្ញ.៩. សមាគមឱសថការី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូង ឬឱសថការីណាម្នាក់ដែលចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីរាជធានី ខេត្តរបស់ខ្លួន រួចហើយធ្វើរបាយការណ៍ផ្ញើជូនគ.ខ្ញ.៩. ។

## ផ្នែកទី២
## ក្រុមប្រឹក្សាគណៈឱសថការីភូមិភាគ

មាត្រា១៩._

ការបែងចែកភូមិភាគសម្រាប់គណៈឱសថការីកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ៖

-ភូមិភាគ១ មានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ

-ភូមិភាគ២ មានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង

-ភូមិភាគ៣ មានខេត្តតាកែវ កំពត កោះកុង ព្រះសីហនុ និងកែប មានទីតាំងនៅខេត្តកំពត

-ភូមិភាគ៤ មានខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង

-ភូមិភាគ៥ មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

មាត្រា២០._

គ.ខ្ញ.ត. មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម មានសមាជិកពេញសិទ្ធិចំនួន៥(ប្រាំ)រូប និងសមាជិកជំនួសចំនួន៥(ប្រាំ)រូប បោះឆ្នោតជ្រើសរើសក្នុងចំណោមគ.ខ្ញ.រ.ខ.ក្នុងភូមិភាគ។ គ.ខ្ញ.រ.ខ.នីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិច១(មួយ)រូបជាសមាជិកពេញសិទ្ធិ និង១(មួយ)រូបជាសមាជិកជំនួស។ ចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកទៅរាជធានី ខេត្ត ដោយផ្អែកលើចំនួនឱសថការីដែលចុះឈ្មោះជាសមាជិកក្រុមប្រឹក្សាភូមិភាគ។ សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល៦(ប្រាំមួយ)ឆ្នាំ។ សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាននិងសមាសភាពនៃការិយាល័យក្នុងរយៈពេល២(ពីរ)ឆ្នាំម្តង ក្រោយពេលធ្វើការផ្លាស់ប្តូរចំនួន១/៣(មួយភាគបី)នៃសមាជិកក្រុមប្រឹក្សា។ សមាជិកជំនួសត្រូវចូលជំនួសសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

សមាសភាពការិយាល័យគ.ខ្ញ.ត. រួមមានប្រធាន១ (មួយ)រូប អនុប្រធាន១ (មួយ)រូប លេខាធិការ១(មួយ)រូប ហេរញ្ញិក១ (មួយ)រូប និងសមាជិក១ (មួយ)រូប ។

មាត្រា២១._

ប្រធានគ.ខ្ញ.រ.ខ. ប្រធានគ.ខ្ញ.ត. និងលេខាធិការនៃក្រុមប្រឹក្សាទាំងនេះ មិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

**មាត្រា២២.-**

អង្គប្រជុំគ.ទ្ធិ.គ.ត្រូវមានការចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់របស់ៈ

- តំណាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្តដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ
- ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយក្រុមប្រឹក្សាអ្នកច្បាប់
- ឱសថការីការងារមួយរូប (បើមាន) ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ។

**មាត្រា២៣.-**

នៅក្នុងក្របខណ្ឌគណៈឱសថការីគ.ទ្ធិ.គ.អនុវត្តការងាររបស់ខ្លួនតែលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

គ.ទ្ធិ.គ.អាចទទួលបណ្តឹងជំទាស់ពី គ.ទ្ធិ.ជ. គ.ទ្ធិ.វ.ខ. សមាគមឱសថការី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធររាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ឬពីឱសថការីណាម្នាក់ ដែលចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ។

គ.ទ្ធិ.គ.ត្រូវពិនិត្យសម្រេចក្នុងរយៈពេល៦(ប្រាំមួយ)ខែយ៉ាងយូរ ក្រោយពេលទទួលពាក្យប្តឹង ។ បើមិនដូច្នោះទេ គ.ទ្ធិ.ជ.អាចបញ្ជូនពាក្យប្តឹងនេះទៅគ.ទ្ធិ.គ.ណាមួយផ្សេងទៀតដែលបានជ្រើសរើស ។

**មាត្រា២៤.-**

ឱសថការីដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជាអាចបកស្រាយបានចំពោះមុខគ.ទ្ធិ.គ.អំពីសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួនតែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬតាមរយៈព្រះរាជអាជ្ញាអមសាលាដំបូងតែប៉ុណ្ណោះ ។

**មាត្រា២៥.-**

ការជាកវិន័យត្រូវធ្វើឡើងនៅចំពោះមុខឱសថការីសាមី ។ ឱសថការីសាមីអាចមានអ្នកការពារ ដែលជាឱសថការី ឬជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រសិនបើឱសថការីសាមី មិនព្រមចូលខ្លួនមកបំភ្លឺគ.ទ្ធិ.គ.តាមការអញ្ជើញចំនួន ៣(បី)លើកដោយគ្មានមូលហេតុច្បាស់លាស់ គ.ទ្ធិ.គ.ត្រូវអនុវត្តតាមចំណុចទី៤ក្នុងមាត្រា២៧នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា២៦.-**

គ.ទ្ធិ.គ.ត្រូវមានបញ្ជីកត់ត្រានៅរាល់ពេលប្រជុំជាកវិន័យ ។ គ.ទ្ធិ.គ.ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវ ដោយមានការបញ្ជាក់និងមានការចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវចោទ

មាត្រា២៧._

ដោយមានការចូលរួមពីផ្នែកវិន័យនៃគ.ខ៊ិ.ជ. គ.ខ៊ិ.ត.អាចដាក់វិន័យដល់សមាជិកដូចខាងក្រោម៖

- ការព្រមាន
- ការស្តីបន្ទោសដោយកត់ទុកនៅក្នុងឯកសារផ្ទាល់ខ្លួន
- ការហាមការប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពី៣(បី)ឆ្នាំ ឬជាអចិន្ត្រៃយ៍ ក្នុងផ្នែកណាមួយ ឬ ជាទូទៅនៃមុខងារឱសថសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់
- ការលុបឈ្មោះចេញពីបញ្ជីគណៈឱសថការីកម្ពុជា ។

ឱសថការីដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណៈឱសថការីកម្ពុជា មិនអាចចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីសម្រេចចុងក្រោយដែលបានលើកឡើង ត្រូវតែផ្សព្វផ្សាយទៅគ្រប់គ.ខ៊ិ.ខ.ខ. ព្រមទាំងទៅគ.ខ៊ិ.ជ. ។ ការសម្រេចរបស់គ.ខ៊ិ.ត.ត្រូវតែមានហេតុផលច្បាស់លាស់ ។

មាត្រា២៨._

ក្រោយពេលទទួលវិន័យហាមការប្រកបវិជ្ជាជីវៈអស់រយៈពេល៣(បី)ឆ្នាំយ៉ាងតិចមក ឱសថការីដែលទទួលវិន័យអាចទទួលការលើកលែងវិន័យពីក្រុមប្រឹក្សាគណៈឱសថការីកម្ពុជា ដែលបានដាក់វិន័យដល់ខ្លួន។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយឱសថការីសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះត្រូវបានបដិសេធ ក្រោយពេលធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសាជាថ្មីអាចធ្វើឡើងក្នុងរយៈពេល១(មួយ)ឆ្នាំទៅមុខទៀត ។

ចំពោះវិន័យអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារឱសថសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់ មិនត្រូវអនុញ្ញាតឱ្យមានការស្នើសុំលើកលែងទេ ។

មាត្រា២៩._

ការអនុវត្តវិន័យចំពោះឱសថការី មិនមែនជាឧបសគ្គរារាំងដល់ការអនុវត្តការដាក់វិន័យខាងរដ្ឋបាល ឬតុលាការឡើយ ។

## ផ្នែកទី៣
## ក្រុមប្រឹក្សាគណៈឱសថការីជាតិ

មាត្រា៣០._

គ.ខ៊ិ.ជ.ត្រូវបានជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល៦ (ប្រាំមួយ)ឆ្នាំ បែងចែកដូចខាងក្រោម៖

- តំណាងខេត្តនីមួយៗចំនួន១(មួយ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាគណៈឱសថការីខេត្តនោះ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះមហាក្សត្រ

- តំណាងរាជធានីចំនួន២ (ពីរ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាគណៈឱសថការីរាជធានី ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

- តំណាងអង្គភាពថ្នាក់កណ្តាលរបស់ក្រសួងសុខាភិបាលចំនួន៥(ប្រាំ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសហភាគៈឱសថការី និងតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

- តំណាងមហាវិទ្យាល័យឱសថសាស្ត្រចំនួន១(មួយ)រូប ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសហភាគៈឱសថការី និងតែងតាំងដោយព្រឹទ្ធបុរសមហាវិទ្យាល័យ ។

**មាត្រា៣១.–**

**គ.ឱ.ជ.**ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួន១/៣(មួយភាគបី)ក្នុងរយៈពេល២(ពីរ)ឆ្នាំម្តង ។ ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិក១/៣(មួយភាគបី)ម្តងៗ **គ.ឱ.ជ.**ត្រូវធ្វើការជ្រើសរើសប្រធាន និងសមាសភាពការិយាល័យរបស់ខ្លួនសម្រាប់២ (ពីរ) ឆ្នាំម្តង ។

សមាសភាពការិយាល័យរបស់**គ.ឱ.ជ.**រួមមាន ៖

ប្រធានក្រុមប្រឹក្សា១(មួយ)រូប អនុប្រធានចំនួន២(ពីរ)រូប អគ្គលេខាធិការ១(មួយ)រូប អគ្គលេខាធិការរង១(មួយ)រូប ហេរញ្ញិក១(មួយ)រូប និងហេរញ្ញិករង១(មួយ)រូប ។ ប្រធាន និងសមាជិក**គ.ឱ.ជ.**ដែលចេញពីតំណែងអាចឈរឈ្មោះឱ្យគេជ្រើសរើសសាជាថ្មីបាន ។

**មាត្រា៣២.–**

**គ.ឱ.ជ.**មានឱសថការីចំនួន២(ពីរ)រូប តំណាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល១(មួយ)រូប និងតំណាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ១(មួយ)រូប ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ ។

**មាត្រា៣៣.–**

**គ.ឱ.ជ.**មានផ្នែកវិន័យមួយដែលមានសមាជិក៥(ប្រាំ)រូប ដឹកនាំដោយប្រធាន១(មួយ)រូប ជ្រើសតាំងក្នុងចំណោមសមាជិក៥(ប្រាំ)រូបនេះ ។

**មាត្រា៣៤.–**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួន១/៣(មួយភាគបី)របស់ខ្លួន **គ.ឱ.ជ.**ត្រូវធ្វើការបោះឆ្នោតជ្រើសរើសផ្នែកវិន័យសាជាថ្មី ។

**មាត្រា៣៥.–**

**គ.ឱ.ជ.**បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួនក្នុងពេលបំពេញបេសកកម្ម ដូចមានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

គ.ឱ.ក.ឃ្លាំមើលជាអាទិ៍ ការគោរពអនុវត្តរបស់សមាជិកនៃគណៈឱសថការីកម្ពុជាទាំងអស់ នូវករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់ក្នុងក្រមសីលធម៌ឱសថការី ។

គ.ឱ.ក.សហការជាមួយគ.ឱ.រ.ខ. ក្នុងការសិក្សាដោះស្រាយបញ្ហាស្មុគស្មាញទាំងឡាយដែលពាក់ព័ន្ធនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ឱសថការី ។

គ.ឱ.ក.បំពេញការងារនេះតាមរយៈផ្នែកនិងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សាបណ្តាបញ្ហាឬគម្រោងការទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា៣៦._**

គ.ឱ.ក.ត្រូវកំណត់អំពីចំនួនទឹកប្រាក់ភាគទានឯកភាពមួយដែលសមាជិកម្នាក់ៗត្រូវបង់ នៅពេលសុំចុះបញ្ជី និងត្រូវបង់ប្រចាំឆ្នាំ ។

គ.ឱ.ក.ត្រូវកម្រិតផងដែរនូវចំនួនភាគទានដែលគ.ឱ.រ.ខ.ត្រូវបង់ជូនទៅគ.ឱ.ក. ទៅគ.ឱ.ត. និងត្រូវរក្សាទុកនៅក្នុងគ.ឱ.រ.ខ. ដើម្បីធានាចំណាយក្នុងការបំពេញការងារទូទៅ ។ ការបង់ភាគទានគឺជាកាតព្វកិច្ចរបស់សមាជិកម្នាក់ៗ ។

គ.ឱ.ក.គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈឱសថការីកម្ពុជា និងអាចបង្កើតឬឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈឱសថសាស្ត្រ ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

គ.ឱ.ក.ត្រួតពិនិត្យការគ្រប់គ្រងរបស់គ.ឱ.រ.ខ. និង គ.ឱ.ត. ។ គ.ឱ.រ.ខ.ត្រូវរាយការណ៍ជូនគ.ឱ.ក. ជាមុនទើបចម្លងជូនទៅគ.ឱ.ត. អំពីការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា៣៧._**

គ.ឱ.ក.ត្រូវបង្កើតគណៈកម្មការសម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង។ សមាជិកនៃគណៈកម្មការនេះត្រូវជ្រើសរើសដោយគ.ឱ.ក. ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យរបស់គ.ឱ.ក. ។

នៅដំណាច់ឆ្នាំនីមួយៗគណៈកម្មការនេះត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូនគ.ឱ.ក. ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា៣៨._**

ក្នុងអាណត្តិទី១នេះ សមាសភាព គ.ឱ.ក.ត្រូវបានជ្រើសតាំងនិងឯកភាពដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីដំណើរការឱ្យមានប្រសិទ្ធភាព ។

ក្នុងអំឡុងពេល៦(ប្រាំមួយ)ឆ្នាំដំបូងនៃអាណត្តិទីមួយ សមាសភាពការិយាល័យរបស់ គ.ឱ.រ.ខ. គ.ឱ.ត.ត្រូវបានជ្រើសតាំងដោយសហភាគៈរបស់ខ្លួន និងទទួលស្គាល់ដោយគ.ឱ.ក. ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

**មាត្រា៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែងតាំងក្រុមការងារមួយជាបណ្តោះអាសន្ន ដើម្បីរៀបចំដំណើរការបង្កើតគណៈឱសថការីកម្ពុជា ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤១.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា នស/រកត.០២១០.១៦៤

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ: ១៥២ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនគេន**

លេខ:៣៧៥ ស.នរប

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

"ដើម្បីផ្សព្វផ្សាយ"

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០១០

អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ

**សាស្ត្រាចារ្យ ភើត-ម៉ៀច**